ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

*ថ្ងៃ អង្គារ ១១ កើត ខែមាឃ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣*
*រាជធានីភ្នំពេញ, ថ្ងៃទី ០៤ ខែកុម្ភៈ ឆ្នាំ២០២០*

# សេចក្តីជូនដំណឹងសម្រាប់សារព័ត៌មានស្តីពី

## ជំនួបពិភាក្សាការងាររវាងឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី អូន ព័ន្ធមុនីរ័ត្ន រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាមួយឯកឧត្តមបណ្ឌិត Park Heung-Kyeong ឯកអគ្គរដ្ឋទូតវិសាមញ្ញ និងពេញសមត្ថភាពនៃសាធារណរដ្ឋកូរ៉េថ្មី ប្រចាំនៅព្រះរាជាណាចក្រកម្ពុជា

នៅរសៀលថ្ងៃទី ០៤ ខែ កុម្ភៈ ឆ្នាំ ២០២០, នៅទីស្តីការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី **អូន ព័ន្ធមុនីរ័ត្ន** រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានអនុញ្ញាតឱ្យ **ឯកឧត្តមបណ្ឌិត Park Heung-Kyeong** ជួបសម្តែងការគួរសម និងពិភាក្សាការងារ ក្នុងខណៈដែលឯកឧត្តមត្រូវបានតែងតាំងជាឯកអគ្គរដ្ឋទូតវិសាមញ្ញ និងពេញសមត្ថភាពនៃសាធារណរដ្ឋកូរ៉េថ្មី ប្រចាំព្រះរាជាណាចក្រកម្ពុជា ។

**ឯកឧត្តមបណ្ឌិត Park Heung-Kyeong** ឯកអគ្គរដ្ឋទូតវិសាមញ្ញ និងពេញសមត្ថភាពនៃសាធារណរដ្ឋកូរ៉េ បានសម្តែងនូវសេចក្តីសោមនស្សរីករាយ ដែលបានមកបំពេញបេសកកម្មការទូតនៅព្រះរាជាណាចក្រកម្ពុជា និងសូមសម្តែងនូវការកោតសរសើរដល់កិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលកម្ពុជា ដែលសម្រេចបាននូវសមិទ្ធផលផ្លែផ្កាជាច្រើន ជាមួយនឹងកំណើនសេដ្ឋកិច្ចខ្ពស់ និងការរីកចម្រើនស្ទើរគ្រប់វិស័យ ក្នុងរយៈពេលជាច្រើនឆ្នាំកន្លងមកនេះ ។ ជាមួយគ្នានេះ, **ឯកឧត្តមបណ្ឌិតឯកអគ្គរដ្ឋទូត** ក៏បានថ្លែងអំណរគុណចំពោះកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលកម្ពុជា ដែលតាមរយៈកិច្ចសហប្រតិបត្តិការនានាកន្លងមក, កិច្ចសហប្រតិបត្តិការប្រទេសទាំងពីរ កម្ពុជា-កូរ៉េ បានសម្រេចនូវសមិទ្ធិផលផ្លែផ្កាជាច្រើន ដូចជា កិច្ចព្រមព្រៀងស្តីពីការមិនយកពន្ធត្រួតគ្នារវាងប្រទេសទាំងពីរដែលទើបបានចុះហត្ថលេខាថ្មីៗ នៅអំឡុងពេលដែល **សម្តេចតេជោ** នាយករដ្ឋមន្ត្រី អញ្ជើញចូលរួមកិច្ចប្រជុំកំពូលរំលឹកខួបអនុស្សាវរីយ៍ទំនាក់ទំនងអាស៊ាន-សាធារណរដ្ឋកូរ៉េ និងកិច្ចប្រជុំកំពូលមេគង្គ-សាធារណរដ្ឋកូរ៉េ នៅសាធារណរដ្ឋកូរ៉េកាលពីចុងខែ វិច្ឆិកា ឆ្នាំ ២០១៩ កន្លងមក ជាដើម ។

**ឯកឧត្តមបណ្ឌិត Park Heung-Kyeong** ក៏បានគូសបញ្ជាក់ជូនថា ក្នុងអាណត្តិបំពេញភារកិច្ចការទូតនេះ ឯកឧត្តមនឹងបន្តខិតខំពង្រឹង និងពង្រីកកិច្ចសហប្រតិបត្តិការលើគ្រប់វិស័យអាទិភាពរបស់រាជរដ្ឋាភិបាលកម្ពុជា ព្រមទាំងបន្តការគាំទ្រនូវការផ្តល់ហិរញ្ញប្បទានសម្រាប់កិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ផ្លូវការ (ODA) ទាំងក្នុងក្របខ័ណ្ឌហិរញ្ញប្បទានឥតសំណង, ឥណទានសម្បទាន, ជំនួយបច្ចេកទេស, និងកម្មវិធីចែករំលែក

ចំណេះដឹង ជាពិសេស ជំរុញការអភិវឌ្ឍវិស័យឯកជននានា ឲ្យកាន់តែរីកចំរើនបន្ថែមទៀត ។ ជាមួយគ្នានេះ, **ឯកឧត្តមបណ្ឌិតឯកអគ្គរដ្ឋទូត** សូមថ្លែងអំណរគុណចំពោះ ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី និងស្ថាប័នពាក់ព័ន្ធ ដែលតែងតែបានផ្តល់នូវកិច្ចសហប្រតិបត្តិការដ៏ល្អប្រសើរ រវាងប្រទេសកម្ពុជា-សាធារណរដ្ឋកូរ៉េ នាពេលកន្លងមក ។

ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី **អូន ព័ន្ធមុនីរ័ត្ន** បានសម្តែងនូវក្តីសោមនស្សរីករាយ និងស្វាគមន៍យ៉ាងកក់ក្តៅ ចំពោះវត្តមាន **ឯកឧត្តមបណ្ឌិត** Park Heung-Kyeong ដែលទើបទទួលបានភារកិច្ចបំពេញបេសកកម្មការទូតនៅកម្ពុជា និងវាយតម្លៃខ្ពស់ចំពោះសមិទ្ធផលផ្លែផ្កាជាច្រើននេះ ដោយកម្ពុជាមានសុខសន្តិភាព ជាមួយនឹងស្ថិរភាពនយោបាយ និងស្ថិរភាពនៃម៉ាក្រូសេដ្ឋកិច្ច និងការអនុវត្តដ៏មុឹងម៉ាត់នូវគោលនយោបាយកំណែទម្រង់នានានៃព្រះរាជាណាចក្រកម្ពុជា ។ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យឧបនាយករដ្ឋ-មន្ត្រី** ក៏បានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះកិច្ចខិតខំប្រឹងប្រែងរបស់រដ្ឋាភិបាលនៃសាធារណរដ្ឋកូរ៉េ ដែលកន្លងមក បានសម្រេចបង្កើនកិច្ចសហប្រតិបត្តិការក្នុងក្របខ័ណ្ឌឥណទានសម្បទានបន្ថែមទៀត តាមរយៈមូលនិធិសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ច (Economic Development Cooperation Fund-EDCF) ដោយបានបង្កើនកញ្ចប់ឥណទានសម្បទានក្នុងកិច្ចសម្របសម្រួល (Framework Arrangement) សម្រាប់ឆ្នាំ ២០១៦-២០១៨ ពីទឹកប្រាក់ចំនួន ៣៥០ លានដុល្លារអាមេរិក ទៅ ៧០០ លានដុល្លារអាមេរិក សម្រាប់ឆ្នាំ ២០១៩-២០២៣ ។ សកម្មភាពទាំងនេះ បានឆ្លុះបញ្ចាំងយ៉ាងច្បាស់ថា សាធារណរដ្ឋកូរ៉េជាដៃគូអភិវឌ្ឍន៍ដ៏សំខាន់ ក្នុងការចូលរួមចំណែកជួយគាំទ្រដល់ប្រទេសកម្ពុជា ។ ជាមួយគ្នានេះ, **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** ក៏បានសម្តែងនូវការកោតសសើរ និងថ្លែងអំណរគុណ ចំពោះលំហូរទុន និងទំហំនៃការវិនិយោគឯកជនពីប្រទេសកូរ៉េខាងត្បូង ដែលមានចំនួនកើតឡើងជាបន្តបន្ទាប់ ដែលបានចូលរួមអភិវឌ្ឍន៍សង្គម-សេដ្ឋកិច្ចកម្ពុជា ។ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ** ក៏ស្នើឯកឧត្តមឯកអគ្គរដ្ឋទូតបន្តជួយសម្របសម្រួលដើម្បីទាក់ទាញអ្នកវិនិយោគទុនឲ្យបានច្រើនបន្ថែមទៀត ។

**ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** ក៏សូមជូនពរឯកឧត្តមបណ្ឌិត **Park Heung-Kyeong** ឲ្យទទួលបាននូវជោគជ័យ សម្រាប់ការបំពេញភារកិច្ចនៅកម្ពុជា។